ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៣ ០២០ ០៨៧ ធ.ជ.ក

ថ្ងៃព្រហស្បតិ៍ ៥កើត ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែមីនា ឆ្នាំ២០២០

# សេចក្តីជូនដំណឹង
## ស្តីពីយុទ្ធនាការស្រឡាញ់ប្រាក់រៀល

ធនាគារជាតិនៃកម្ពុជាមានសេចក្តីសោមនស្សរីករាយ សូមជម្រាបជូនសាធារណជនឱ្យបានជ្រាបថា ដើម្បីអបអរសាទរខួបលើកទី៤០ នៃការដាក់ឱ្យចរាចរប្រាក់រៀលឡើងវិញ និងពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរខាងមុខ ធនាគារជាតិនៃកម្ពុជានឹងរៀបចំយុទ្ធនាការស្រឡាញ់ប្រាក់រៀល ចាប់ពីថ្ងៃសុក្រ ១២រោច ខែផល្គុន ដល់ថ្ងៃសុក្រ ៣រោច ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹង**ថ្ងៃទី២០ ខែមីនា ដល់ថ្ងៃទី១០ ខែមេសា ឆ្នាំ២០២០។**

យុទ្ធនាការនេះ នឹងផ្តល់ឱកាសជូនសាធារណជនដែលមានក្រដាសប្រាក់រៀលចាស់ ទក់ ឬរហែក អញ្ជើញមកដូរយកក្រដាសប្រាក់រៀលថ្មី នៅតាមបញ្ជរបេឡារបស់សាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត (លើកលែងស្នាក់ការកណ្តាល) រៀងរាល់ម៉ោងធ្វើការ។

ក្នុងឱកាសនេះ ធនាគារជាតិនៃកម្ពុជា សូមគោរពជូនពរ សម្តេច ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី អ្នកនាងកញ្ញាទាំងអស់ សូមជួបប្រទះពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូមអរគុណ!

ព្រះរាជាណាចក្រកម្ពុជា
ធនាគារជាតិនៃកម្ពុជា

ទំនាក់ទំនងព័ត៌មានបន្ថែម៖
ទូរស័ព្ទ៖ ០២៣-៩៩០-១៩៦
អ៊ីម៉ែល៖ nbccommunication@nbc.org.kh